49/05

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី
លេខ: ២០៧
ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១២
<u>សាលដីកា</u>
លេខ: ៥៧១ "ញ"
ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣

<u>សាលដីកា</u>
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការជាសាធារណៈ នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ។

សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី
លោកស្រី [redacted]

តំណាងមហាអយ្យការ
លោក [redacted] ជាព្រះរាជអាជ្ញា

<u>ដើមចោទ:</u> ឈ្មោះ [redacted] សុផារ៉ុម (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៧ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិក្បាលកោះ សង្កាត់កោះទ្រង់ ក្រុងក្រចេះ ខេត្តក្រចេះ ។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

<u>ចុងចម្លើយ:</u> ឈ្មោះ [redacted] រិទ្ធី (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិកណ្តាលកោះ សង្កាត់កោះទ្រង់ ក្រុងក្រចេះ ខេត្តក្រចេះ។

<u>កម្មវត្ថុបណ្តឹង:</u>

-សុំបដិសេធលក្ខន្តិកៈផ្ទេរមរតក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៣ ។



មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia



Scanned with CamScanner

49
ចម

-សុំគ្រប់គ្រងដីភូមិទំហំ ៩ម គុណ ២៨០ម និងផ្ទះទំហំ ៩,៧ម គុណ ១២ម ។

**អំពីអង្គហេតុ និង ចំណុចវិវាទ**

**ក.អំពីអង្គហេតុ ជាមូលហេតុនៃការទាមទារ:**

តាមពាក្យបណ្ដឹង ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១០ របស់ដើមចោទឈ្មោះ [redacted] សុផារ៉ុម បញ្ជាក់ថា: កាលពីឆ្នាំ១៩៧៩ ម្ដាយខ្លួន និងក្រុមគ្រួសារបានមករស់នៅកាន់កាប់គ្រប់គ្រងដី និងផ្ទះនៅឆ្នាំ២០០១ ខ្លួនបានទៅរកការងារធ្វើនៅភ្នំពេញ ហើយបានទៅមកថែរក្សាដី ផ្ទះ និងម្ដាយ ព្រមទាំងបានផ្ដល់ប្រាក់មកឲ្យម្ដាយ និងកូនជាប្រចាំ ។ លុះដល់ឆ្នាំ២០០៣ ម្ដាយខ្លួនបានទទួលមរណៈភាព ដោយខ្លួនមិនបានដឹងទេ រហូត ១៥ថ្ងៃ ក្រោយមក ទើបបានទទួលដំណឹងនេះ ប៉ុន្តែពិធីបុណ្យសពគេធ្វើរួចរាល់ហើយ ។ ចំណែកដី ផ្ទះនេះមានបងស្រីឈ្មោះ [redacted] សារ៉ាត់ និងកូនខ្លួនរស់នៅចំនួន ២នាក់ រហូតដល់ថ្ងៃទី១៣-៨-២០១០ ឈ្មោះ [redacted] សារ៉ាត់ ជាបងស្រីទទួលមរណៈភាពដែរ ខ្លួនបានចាត់ចែងធ្វើបុណ្យសពនេះ ជាម្ចាស់ដើមបុណ្យ ។ នៅយប់ថ្ងៃទី១៩-៨-២០១០ ឈ្មោះ [redacted] រួត បានយកលក្ខន្តិកៈផ្ទេរមរតកមកឲ្យខ្លួនមើល ។ ផ្ទះ ដីដែលខ្លួនកាន់កាប់គ្រប់គ្រងតាំងពីឆ្នាំ១៩៧៩ បែរជាប្រគល់ទៅឲ្យអ្នកដែលមិនបានគ្រប់គ្រងថែរក្សាទៅវិញ ខ្លួនបដិសេធលក្ខន្តិកៈនេះ ។

បានឃើញសាលដីការរដ្ឋប្បវេណីលេខ ០៨(គ) ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តក្រចេះ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១-បដិសេធលក្ខន្តិកៈផ្ទេរមរតក ចុះថ្ងៃទី២២-០១-២០០៣ ចោលជាអសារបង់ ។

២-ទទួលស្គាល់ការទាមទាររបស់ដើមចោទពីសិទ្ធិគ្រប់គ្រងដីទំហំ ក្បាល ៩ម៉ែត្រ បណ្ដោយ ២៨០ម៉ែត្រ និងផ្ទះក្បឿង ៣ខ្នង សង់ពីឈើលើដីនេះ ទំហំ ៩,៧ម៉ែត្រ បណ្ដោយ ១២ម៉ែត្រ មានទីតាំងស្ថិតនៅភូមិក្បាលកោះ សង្កាត់កោះទ្រង់ ក្រុងក្រចេះ ខេត្តក្រចេះ មានព្រំប្រទល់: ខាងជើងជាប់ឈ្មោះ [redacted] ស៊ីយ៉ូត ,ខាងត្បូងជាប់ [redacted] ហារ៉េត ,ខាងលិចជាប់ទន្លេមេគង្គ , ខាងកើតជាប់ [redacted] នឹម ព្រមទាំងប្រគល់ដី និងផ្ទះនេះឲ្យដើមចោទឈ្មោះ [redacted] សុផារ៉ុម គ្រប់គ្រង កាន់កាប់ចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

៤-សាលក្រមនេះ ទាញហេតុផលដោយផ្ទាល់មាត់ចំពោះមុខគូភាគី និងប្រកាសជាសាធារណៈនៅថ្ងៃទី២៥-១០-២០១០ ។ បើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ១៦ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] រិទ្ធី ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០៨(គ) ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ របស់សាលាដំបូងខេត្តក្រចេះ គ្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការរដ្ឋប្បវេណីលេខ ០២ "ក្រ VI យ" ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ



Scanned with CamScanner

49
03

១-ច្រានបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០៤-១១-២០១០ របស់ឈ្មោះ [redacted] រិទ្ធី ។

២-តម្កល់សាលក្រមលេខ ០៨(គ) ចុះថ្ងៃទី២៥-១០-២០១០ របស់ដំបូងខេត្តក្រចេះ ទុកជាបានការដដែល ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយ ។

៤-សាលដីកានេះ ប្រកាសជាសាធារណៈនៅថ្ងៃទី៣០-០១-២០១២ ។

-បើកផ្លូវប្តឹងសាទុក្ខរយៈពេល ១ខែ ក្រោយពីបានទទួលលិខិតជូនដំណឹងអំពីសាលដីកានេះ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៤៩ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] រិទ្ធី ប្តឹងមិនសុខនឹងសាលដីការដ្ឋប្បវេណីលេខ ០២"ក្រ VI យ "ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**ខ.អំពីសេចក្តីថ្លែងការណ៍របស់គូភាគី:**

ឈ្មោះ [redacted] រិទ្ធី ជាម្ចាស់បណ្តឹងសាទុក្ខ បានធ្វើសេចក្តីថ្លែងការណ៍ នាពេលសវនាការថា: ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ ខុសទៅនឹងឆន្ទៈរបស់យាយខ្លួន និងប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួនផង ,មានន័យថា ដីនេះយាយខ្លួនឈ្មោះ [redacted] រិន បានប្រគល់ឲ្យម្តាយខ្លួន ហើយម្តាយខ្លួនមុនពេលទទួលមរណៈភាព ក៏បានផ្ទេរមរតកនេះ មកឲ្យខ្លួនជាកូនគ្រប់គ្រង ។ ហើយការផ្ទេរដីនេះ ពីយាយ [redacted] រិន មកម្តាយខ្លួននោះ គឺមានលក្ខខណ្ឌចិញ្ចឹមយាយ [redacted] រិន ជាម្តាយអស់មួយជីវិត តែអនុញ្ញាតឲ្យឈ្មោះ [redacted] ភ័ក់ រស់នៅផងដែរ តែមិនមានសិទ្ធិទាមទារមរតកនេះទេ ។

<u>**សំណូមពរ:**</u> សុំសិទ្ធិកាន់កាប់ដីជាមរតកពីម្តាយស្របច្បាប់ ។

ឈ្មោះ [redacted] **សុផារ៉ុម** ជាចុងបណ្តឹងសាទុក្ខបានធ្វើសេចក្តីថ្លែងការណ៍នាពេលសវនាការថា: ខ្លួនសុំបដិសេធលក្ខន្តិកៈនោះចោលទាំងស្រុង ព្រោះខ្លួនជាអ្នករស់នៅលើដីនេះ តាំងពីឆ្នាំ១៩៧៩ មក ទោះបីជាខ្លួនមិនបានរស់នៅជាប់លាប់លើដីនេះ ក៏ដោយក៏ខ្លួនមានកូនរស់នៅលើដីនេះដែរ ហើយខ្លួនទៅរកស៊ីក៏មែនពិត តែខ្លួនមិនដែលបានបោះបង់ដី និងផ្ទះចោលនោះទេ តែងតែមកថែទាំជាប្រចាំ ។ ចំពោះរឿងសំពម្តាយ ទោះខ្លួនមិននៅជិតគាត់ជាប់លាប់ក៏ខ្លួនបានផ្ញើរជូនម្តាយជាហូរហែរ រហូតដល់គាត់ទទួលមរណៈភាពក៏ខ្លួនជាអ្នកធ្វើបុណ្យ និងដឹករណ្តៅខ្មោចដោយខ្លួនផ្ទាល់ ។

លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ [redacted] **សុផារ៉ុម** បានធ្វើសេចក្តីសន្និដ្ឋាននាពេលសវនាការថា: ដី និងផ្ទះទំនាស់នេះ គឺយាយ [redacted] រិន បានផ្ទេរឲ្យកូនក្តីខ្ញុំតាំងពីឆ្នាំ១៩៩៩ ដោយមានសៀវភៅគ្រួសារជាភស្តុតាង ហើយសៀវភៅនេះនិងការបោះបុម្ពផ្សាយបានបញ្ជាក់ពីភាពត្រឹមត្រូវស្របច្បាប់របស់កូនក្តីខ្ញុំដែលជាអ្នកកាន់កាប់ដី និងផ្ទះនេះ រីឯការអះអាងរបស់ឈ្មោះ [redacted] រិទ្ធី គឺគ្មានភស្តុតាងនោះទេ ហើយឈ្មោះនេះ ក៏មិនបានកាន់កាប់ដី

ជាក់ស្ដែងដែរ ,លក្ខន្តិកៈដែលគេអះអាងនោះ គឺធ្វើឡើងដោយបិទបាំងមិនឲ្យកូនក្តីខ្ញុំដឹងនោះទេ ទើបតែប្អូនរបស់កូនក្តីខ្ញុំទទួលមរណៈភាពទៀត ក៏មានការបង្ហាញលិខិតនេះ ដូច្នេះ មិនត្រឹមត្រូវតាមច្បាប់នោះទេ ។ ហេតុនេះ សាលដីកាសាលាឧទ្ធរណ៍ សម្រេចសេចក្តីមកត្រឹមត្រូវហើយ ។

**សំណូមពរ:** សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការ ។

-ក្រោយពីស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី និងមេធាវីតំណាងដោយអាណត្តិរបស់ដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា: បណ្តឹងសាទុក្ខលេខ ២៤៩ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១២ របស់ភាគីចុងចម្លើយឈ្មោះ [redacted] រិទ្ធី ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជម្រះក្តី និងមាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-យល់ឃើញថា: ការដែលសាលាឧទ្ធរណ៍ សម្រេចតម្កល់សាលក្រមរដ្ឋប្បវេណីរបស់សាលាដំបូងខេត្តក្រចេះ ទុកជាបានការ ដោយបដិសេធលក្ខន្តិកៈផ្ទេរមរតក ហើយទទួលស្គាល់សិទ្ធិគ្រប់គ្រងដី និងផ្ទះទំនាស់របស់ភាគីដើមចោទនោះ មិនទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេ ព្រោះថា:

-គ្មានសំអាងហេតុក្នុងការសម្រេចបដិសេធលក្ខន្តិកៈ

-មិនបានពិចារណាអំពីអ្នកចូលរួមផ្តិតមេដៃលើលក្ខន្តិកៈដែលសុទ្ធតែជាកូនរបស់មរតកជន ។

-កាលបរិច្ឆេទមរណភាព មិនទាន់ច្បាស់លាស់ ។

-យល់ឃើញថា: សាលដីការដ្ឋប្បវេណីលេខ ០២" ក្រ VI យ "ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មិនត្រឹមត្រូវទេ ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ២៤៩ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១២ របស់ភាគីចុងចម្លើយ ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ០២" ក្រVIយ " ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ២០៧ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១២ របស់តុលាការកំពូល ត្រឡប់ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ដើមចោទ ។

៥-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ប្រធាន |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោក | | ចៅក្រម |
| លោកស្រី | | ក្រឡាបញ្ជី |

---

បានចម្លងចេញពីច្បាប់ត្រូវតាមច្បាប់ដើម ។

រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៤

ប្រធាន

[redacted]